នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៦ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 07-Jun-2016, 15:35
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារៈ សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះសាលាដំបូងៈ សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារៈ

ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញៈ

ឈ្មោះមន្ត្រីដែលបានពិនិត្យៈ

ហត្ថលេខាៈ

---

## សំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យធ្វើការស៊ើបអង្កេតទាក់ទងនឹង
## ធឿន ទុទ្ធី អនុលោមតាមវិធាន ៩៣ នៃវិធានផ្ទៃក្នុង

---

**អ្នកដាក់ឯកសារៈ**

**សហព្រះរាជអាជ្ញា**

លោក Nicholas KOUMJIAN

លោកស្រី ជា លាង

**អ្នកទទួលឯកសារៈ**

**អង្គជំនុំជម្រះសាលាដំបូង**

ចៅក្រម និល ណុន, ប្រធាន

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម យ៉ា សុខន

ចៅក្រម Claudia FENZ

ចៅក្រម យូរ ឧត្តរា

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

លោក ពេជ អង្គ

លោកស្រី Marie GUIRAUD

**ចម្លងជូនៈ**

**ជនជាប់ចោទ**

នួន ជា

ខៀវ សំផន

**មេធាវីការពារក្តីជនជាប់ចោទ**

លោក សុន អរុណ

លោក Victor KOPPE

លោក គង់ សំអុន

លោកស្រី Anta GUISSÉ

**មេធាវីប្រចាំការ**

ទូច វរលក្ខណ៍

Calvin SAUNDERS

## I. សំណើ

1. ទាក់ទងនឹងចេតនាដែលបានថ្លែងរបស់អង្គជំនុំជម្រះសាលាដំបូង កោះហៅ វឿន វុទ្ធី ឱ្យមកផ្ដល់សក្ខីកម្មនៅថ្ងៃដែលមិនបានកំណត់ជាក់លាក់[1] សហព្រះរាជអាជ្ញាជូនសេចក្ដីសន្និដ្ឋានថា សំណើសុំឱ្យធ្វើកិច្ចស៊ើបសួរនេះ អនុលោមតាមវិធាន៩៣ នៃវិធានផ្ទៃក្នុង។ វិធាន៩៣ នៃវិធានផ្ទៃក្នុង ចែងថា "ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ការស៊ើបសួរថ្មីជាការចាំបាច់ អង្គជំនុំជម្រះសាលាដំបូង អាចបង្គាប់ឱ្យធ្វើការស៊ើបសួរបន្ថែមបានគ្រប់ពេលវេលា"។ ភាពចាំបាច់នៃកិច្ចស៊ើបសួរត្រូវតែធ្វើយុត្តិកម្មដោយផលប្រយោជន៍នៃយុត្តិធម៌[2]។

2. អង្គជំនុំជម្រះសាលាដំបូងធ្លាប់បានទទួលធ្វើជាភស្តុតាង[3] នូវអត្ថបទមួយពីកាសែតភ្នំពេញប៉ុស្តិ៍ ក្រោមចំណងជើងថា "លលាដ៍ក្បាល ដោយ លលាដ៍ក្បាល, ក្រុមការងារធ្វើបញ្ជីការសម្លាប់របស់ខ្មែរ ក្រហម"[4] ("អត្ថបទកាសែត")។ អត្ថបទកាសែតនេះ រៀបរាប់ពីការស៊ើបអង្កេតមួយដែលមានរយៈពេលពីរឆ្នាំ ត្រូវបានធ្វើឡើងនៅជើងឯក ដោយ វឿន វុទ្ធី និងអ្នកស៊ើបអង្កេតមួយក្រុម "ដែលបានស្វែងរកទិន្នន័យដែលពួកគេអាចប្រើប្រាស់បានសម្រាប់សន្និដ្ឋានអាយុ ភេទ និងរបៀបនៃការស្លាប់របស់ជនរងគ្រោះ"[5]។ អង្គជំនុំជម្រះសាលាដំបូងក៏ធ្លាប់បានទទួលយកធ្វើជាភស្តុតាង

---

[1] **E404/4,** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ស្ដីពី "សេចក្ដីសម្រេចលើការទទួលយកជាភ័ស្តុតាងនូវឯកសារសិក្សាពីជើងឯក", ២៣ ឧសភា ២០១៦, កថាខណ្ឌ៧។

[2] **E294/1** សេចក្ដីសម្រេចលើសំណើរបស់ នួន ជា ស្នើសុំឱ្យទទួលយកភស្តុតាងថ្មី, ឱ្យចាប់ផ្ដើមការស៊ើបអង្កេត និងឱ្យកោះហៅលោក ROB LEMKIN, ២៤ កក្កដា ២០១៣, កថាខណ្ឌ១១។

[3] ព្រាងប្រតិចារឹក, ២១ មេសា ២០១៦, ម៉ោង ១១.៤២.២៥។

[4] Crane, Brent, "លលាដ៍ក្បាល តាម លលាដ៍ក្បាល, ក្រុមការងារធ្វើបញ្ជីការសម្លាប់របស់ខ្មែរក្រហម", កាសែតភ្នំពេញប៉ុស្តិ៍, ៦ កុម្ភៈ ២០១៦, អាចរកបាននៅត្រង់ http://www.phnompenhpost.com/post-weekend/skull-skull-team-catalogues-kr-killings (បើកមើលចុងក្រោយនៅថ្ងៃទី២ ខែមិថុនា ឆ្នាំ២០១៦)។ ទោះបីជាបានទទួលយក សហព្រះរាជអាជ្ញាកត់សម្គាល់ថា អត្ថបទកាសែតនេះមិនបានដាក់ចូលទៅក្នុងសំណុំរឿង នៅក្នុង Zylab នៅឡើយទេ។

[5] Crane, Brent, "លលាដ៍ក្បាល តាម លលាដ៍ក្បាល, ក្រុមការងារធ្វើបញ្ជីរាយការសម្លាប់របស់ខ្មែរក្រហម", កាសែតភ្នំពេញប៉ុស្តិ៍, ៦ កុម្ភៈ ២០១៦, អាចរកបាននៅត្រង់ http://www.phnompenhpost.com/post-weekend/skull-skull-team-catalogues-kr-killings (បើកមើលចុងក្រោយនៅថ្ងៃទី២ ខែមិថុនា ឆ្នាំ២០១៦)។

ផងដែរនូវផ្នែកនានានៃការសិក្សានៅជើងឯក ដែលបានលេចចេញមកពីកិច្ចស៊ើបអង្កេតនោះ ក៏ដូចជារបាយការណ៍វាយតម្លៃលើគម្រោងសិក្សានៅជើងឯក[6]។

3. អង្គជំនុំជម្រះសាលាដំបូងធ្លាប់បានទទួលយកសំណើរបស់ នួន ជា សុំឲ្យ វឿន វុទ្ធី មកបង្ហាញខ្លួនជាសាក្សីនៅក្នុងសំណុំរឿង០០២/០២[7]។ ទាក់ទងទៅនឹងសក្ខីកម្មនោះ ហើយជាប្រយោជន៍នៃការស្វែងរកការពិតនៅក្នុងសំណុំរឿង០០២/០២ សហព្រះរាជអាជ្ញាសុំឲ្យអង្គជំនុំជម្រះសាលាដំបូងស្វែងរកដើម្បីឲ្យបានទទួលនូវព័ត៌មានចំនួនពីរប្រភេទដូចតទៅ ពី វឿន វុទ្ធី មុនពេលគាត់ចូលមកបង្ហាញខ្លួនក្នុងឋានៈជាសាក្សីម្នាក់។ នៅលើមូលដ្ឋាននៃព័ត៌មានដែលមាននៅក្នុងអត្ថបទកាសែត ព័ត៌មានដែលបានស្នើសុំនេះ ទំនងជាអាចរកបានចំពោះ វឿន វុទ្ធី។ សហព្រះរាជអាជ្ញាសន្និដ្ឋានថា ការធ្វើឲ្យព័ត៌មាននេះអាចរកបានចំពោះភាគីនានា ឲ្យបានមុនពេលដែល វឿន វុទ្ធី ចូលមកបង្ហាញខ្លួនក្នុងឋានៈជាសាក្សីម្នាក់នោះ នឹងទំនងជាធ្វើឲ្យសក្ខីកម្មរបស់គាត់កាន់តែភ្លឺជាងមុនអំពីបញ្ហានានាក្នុងសវនាការ។

4. ទាក់ទងនឹងព័ត៌មានប្រភេទទីមួយ អត្ថបទកាសែតបានថ្លែងដូចតទៅ៖

> ដើម្បីបំពេញការងារធ្វើកោសលវិច័យ វុទ្ធី បានសម្ភាសអ្នកសម្លាប់បួន-ប្រាំនាក់នៅជើងឯក ដែលខ្សែវីឌីអូនឹងត្រូវបានចេញផ្សាយនៅឆ្នាំក្រោយ។ ម្នាក់ក្នុងចំណោមអ្នកសម្លាប់នោះគឺ ហ៊ីម ហ៊ុយ ជាប្រធានក្រុមអ្នកយាមទទួលខុសត្រូវក្នុងការសម្លាប់នៅទីនោះ។ អ្នកដែលមានអាយុច្រើន ហ៊ុយ ដែលមិនត្រូវបានជំនុំជម្រះអំពីឧក្រិដ្ឋកម្មរបស់គាត់ បានតក់ស្លុតក្នុងអំឡុងពេលបើកការសម្ភាសគាត់ចំនួនពីរម៉ោង។ "អ្វីៗ គាត់បានប្រាប់ពួកយើងអស់", វុទ្ធី និយាយ។
>
> ហ៊ុយ បានអះអាងភាគច្រើននៃវិធីសាស្ត្រសម្លាប់ទៅ វុទ្ធី ហើយក្រុមការងាររបស់គាត់បានសន្និដ្ឋាន ប៉ុន្តែគាត់បានបន្ថែមសេចក្តីពិស្តារ។ ថ្ងៃភាគច្រើន ការសម្លាប់ចាប់ផ្តើមនៅម៉ោង៦ល្ងាច ហើយវាមិនចប់ទេរហូតដល់ពាក់កណ្តាលអធ្រាត្រ,

---

6 **E404/4**, អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពី "សេចក្តីសម្រេចលើការទទួលយកជាភ័ស្តុតាងនូវឯកសារសិក្សាពីជើងឯក", ២៣ ឧសភា ២០១៦។

7 **E404/4**, អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពី "សេចក្តីសម្រេចលើការទទួលយកជាភ័ស្តុតាងនូវឯកសារសិក្សាពីជើងឯក", ២៣ ឧសភា ២០១៦។

ហ៊ុយ និយាយ។ ពួកគេមិនដែលសម្លាប់មនុស្សទេនៅពេលថ្ងៃ។ ឆ្នាំដែលមានឈាមច្រើនបំផុត គឺឆ្នាំ១៩៧៨, យោងទៅតាម ហ៊ុយ។

5. សហព្រះរាជអាជ្ញាស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូងបានទទួលនូវប្រតិចារឹក ដែលអាចរកបានណាមួយ និង/ឬ ខ្សែវីឌីអូនៃបទសម្ភាសដែលបានរៀបរាប់។ ភស្តុតាងនេះអាចទាក់ទងទៅនឹងសំណុំរឿង00២/0២ គឺទីកន្លែងឧក្រិដ្ឋកម្មនៅជើងឯក[8] ហើយអាចមាននូវសេចក្តីថ្លែងយ៉ាងហោចណាស់ក៏បុគ្គលម្នាក់ដែរ ដែលធ្លាប់បានផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះនេះ នៅក្នុងសំណុំរឿង00២/0២ គឺ ហ៊ឹម ហ៊ុយ[9]។ ដូច្នេះ ការបានព័ត៌មាននេះ អាចបានជាប្រយោជន៍នៃយុត្តិធម៌។

6. ទាក់ទងទៅនឹងប្រភេទទីពីរនៃព័ត៌មាន អត្ថបទកាសែតបានថ្លែងថា៖ "វុទ្ធី និងក្រុមការងាររបស់គាត់ មានផែនការបន្តកិច្ចការរបស់ពួកគេនៅទីកប់សពថ្មីមួយ គឺក្រាំងតាចាន់ ក្នុងខេត្តតាកែវ ដែលមានសាកសព ១0000 នាក់ ត្រូវបានជីកកកាយ"។ សហព្រះរាជអាជ្ញាស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូង ទទួលព័ត៌មានណាក៏ដោយដែលអាចរកបាន ចំពោះ វឿន វុទ្ធី និងក្រុមរបស់គាត់ដែលខ្វល់ខ្វាយពីការងាររបស់ពួកគាត់នៅក្រាំងតាចាន់ ឬនៅមុនពេលដែលគេគាស់ចេញពីក្នុងដី ឬប្រមូលឆ្អឹងពីទីកន្លែងនោះ។ ព័ត៌មាននេះអាចទាក់ទងទៅនឹងសំណុំរឿង00២/0២ គឺទីកន្លែងឧក្រិដ្ឋកម្មនៅក្រាំងតាចាន់[10]។ ដូច្នេះ ការរកបានព័ត៌មាននេះ អាចបានជាប្រយោជន៍នៃយុត្តិធម៌។

---

[8] **E301/9/1.1** បញ្ជីកថាខណ្ឌ និងផ្នែកនានានៃដីកាដំណោះស្រាយដែលទាក់ទងនឹងការជំនុំជម្រះ សំណុំរឿងលេខ 00២/0២, ៤ មេសា ២0១៤, កថាខណ្ឌ៣(vi)។ **D427** ដីកាដំណោះស្រាយលើសំណុំរឿង00២, ១៥ កញ្ញា ២0១0, កថាខណ្ឌ៤១៥ ("មន្ទីរសន្តិសុខ ស-២១ (ស-២១) រួមមាន មន្ទីរឃុំឃាំងមួយនៅទីក្រុងភ្នំពេញ និងកន្លែងសម្លាប់មនុស្សមួយនៅជើងឯក ដែលស្ថិតនៅចម្ងាយ១៥គីឡូម៉ែត្រ នៅភាគនិរតីនៃទីក្រុងភ្នំពេញ ក្នុងខេត្តកណ្តាល")។

[9] ហ៊ឹម ហ៊ុយ បានផ្តល់សក្ខីកម្មនៅថ្ងៃទី ៣, ៤ និង ៥ ខែឧសភា ឆ្នាំ២0១៦។

[10] **E301/9/1.1** បញ្ជីកថាខណ្ឌ និងផ្នែកនានានៃដីកាដំណោះស្រាយដែលទាក់ទងនឹងការជំនុំជម្រះ សំណុំរឿងលេខ00២/0២, ៤ មេសា ២0១៤, កថាខណ្ឌ៣(vii)។

## III. ដំណោះស្រាយដែលបានស្នើសុំ

7. ដូច្នេះ សហព្រះរាជអាជ្ញាស្នើសុំដោយគោរពដល់អង្គជំនុំជម្រះសាលាដំបូងឲ្យទទួលព័ត៌មាន ដែលបានរៀបរាប់ខាងលើនេះ និងផ្តល់ព័ត៌មាននោះឲ្យទៅភាគីនានានៅក្នុងសំណុំរឿង០០២/០២៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៦ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | [signature] |
| | **លោក** Nicholas KOUMJIAN<br>សហព្រះរាជអាជ្ញា | | [signature] |